ព្រះរាជាណាចក្រកម្ពុជា

**តុលាការកំពូល** ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ **សាលដំបូងថ្នាក់ខេត្ត** (តុលាការកំពូល)

**សាលដីកាតុលាការកំពូល**

លេខ : ៦៥

ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៥

**សាលដីកា** បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១០ ខែ ឧសភា

លេខ : ៤២ ឆ្នាំ ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន

២- លោក ឈឹម ស៊ីផល ចៅក្រម

៣- លោក វៀល មួន ចៅក្រម

៤- លោក ស៊ិន ឌឹម ចៅក្រម

៥- លោក យស់ សូឌឿន ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

លោក **គីម ថាវរ៉ូ**

តំណាងមហាអយ្យការ

ឯកឧត្តម **ហ៊ួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ៦៤"យ"ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៦៥ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

***ពិរុទ្ធ*** : ធ្វើមនុស្សឃាដដោយចេតនា ប្រព្រឹត្តនៅភូមិក្រូច ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិ មាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះចិន ឌុន ( ជាចុងបណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិត្រាំងពោធិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិក្រូ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ។ ឪពុកឈ្មោះសួន ចិន "រ" ម្ដាយឈ្មោះហម គីម "ស" ប្រពន្ធឈ្មោះផាំ ផល្លី មានកូន ០៥នាក់ ។ ចាប់ខ្លួន ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៩ ឃុំខ្លួនថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៩៩ ។

-មានមេធាវីការពារ លោក សំ ចំរើន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះទី ប៉ោ ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើចំការ ទីលំនៅ សព្វថ្ងៃភូមិត្រាំងពោធិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ។

-ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ "ជាម្ចាស់បណ្តឹងសាទុក្ខ" ។

-កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៩ វេលាម៉ោង៨.៣០នាទីយប់ លោកប៊ិន សុជាត មេឃុំ ពត់សរ ស្រុកបាទី បានចាត់កំលាំងកងជីវពលឃុំចំនួន០៥នាក់ ចុះទៅបង្ក្រាប បទល្មើសឆក់ត្រី ក្នុងនោះ មាន ចិន ខុន ចូលរួមផងដែរ ។ ក្នុងពេលបង្ក្រាបនៅបឹងហង់ខ្លា ក៏ជួបអ្នកឆក់ត្រី ហើយពួកនោះបាននាំគ្នារត់ ឈ្មោះចិន ខុន ឃើញដូច្នេះក៏បាញ់ទៅលើ និង ស្រែកឱ្យពួកគេឈប់ តែពួកគេនៅតែរត់ដដែល ខណៈ សេនាជនទាំង០៥នាក់ ក៏បានដេញតាម ហើយបានផ្ទុះអាវុធព្រមគ្នា ហើយបណ្តាលឱ្យជនរងគ្រោះឈ្មោះ ប៉ោ សាន្ត ដួលស្លាប់នៅនឹងកន្លែងតែម្តង ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តតាកែវ ថា : ចោទប្រកាន់ លើឈ្មោះចិន ខុន ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ របររកស៊ីជាកងជីវពល ឃុំពត់សរ ស្រុកបាទី ទីលំនៅ សព្វថ្ងៃភូមិក្រូច ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ឪពុកឈ្មោះសួន ចិន "រ" ម្តាយឈ្មោះហម ធីម "ស" ប្រពន្ធឈ្មោះឆាំ ផល្លី មានកូន០៥នាក់ ។ ទោសពីមុនគ្មាន ។ ពីបទ មនុស្សឃាដដោយចេតនា ប្រព្រឹត្តនៅ បឹងហង់ខ្លា ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៩ បទល្មើសដែលមាន ចែងឱ្យផ្តន្ទាទោសតាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៥ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩ របស់តុលាការខេត្ត តាកែវ ដែលបានសំរេច :

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះចិន ខុន ភេទប្រុស អាយុ៣៧ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិ ក្រូច ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ដាក់ពន្ធនាគារកំណត់០៨ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួន ។

ពីបទ : សំលាប់មនុស្សដោយចេតនា ប្រព្រឹត្តនៅភូមិក្រូច ឃុំពត់សរ ស្រុកបាទី ខេត្ត តាកែវ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៩ តាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់អោយឈ្មោះចិន ខុន សងជម្ងឺចិត្តជាប្រាក់ចំនួន៥.០០០.០០០រៀល ( ប្រាំលាន រៀល) អោយទៅឈ្មោះទី ប៉ោ ជាដើមបណ្តឹងរដ្ឋប្បវេណី ឯការទាមទារលើសពីនេះ ត្រូវលើកចោល ។ បើរឹងទទឹងមិនព្រមបង់សងទេនោះ អនុញ្ញាតិឱ្យដាក់គុកបង្ខំលើរូបកាយ ដើម្បីទាមទារធនទណ្ឌខាងលើ តាមមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយ ។

៣-វត្ថុតាងមាន អាវុធAK មួយដើមលេខ៩១០៧ បង់មួយ សំរេចរឹបអូសទុកជា សម្បត្តិរដ្ឋ ។ អាគុយម៉ាកគូក្ស ៤០អំពែ មួយគ្រឿង . ខ្សែភ្លើង២ម៉ែត្រ . ធុងដាក់ត្រីមួយ សំរេចរឹបអូស និង បំផ្លាញចោល ។

សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់៦០ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះចិន ខុន ដែលប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌ២៥ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩ របស់តុលាការខេត្តតាកែវ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា : សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០១ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៦៤"ឃ" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ របស់ឈ្មោះចិន ខុន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ២៥ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩ របស់តុលាការខេត្តតាកែវ ទុកជាបានការ ដោយគ្រាន់តែបន្ថយរយៈពេលផ្តន្ទាទោស ចិន ខុន ពី០៨ឆ្នាំ មកត្រឹម០៦ឆ្នាំ (ប្រាំមួយឆ្នាំ) វិញ តាមមាត្រា៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង បង្គាប់ឱ្យអាជ្ញាធរឃុំពត់សរ សងជម្ងឺចិត្តជាប្រាក់ចំនួន៥លានរៀល (ប្រាំលាន) ឱ្យទៅឈ្មោះទី ហ៊ោ ជាដើមបណ្តឹង ។ ចំណុចផ្សេងទៀតរក្សាទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវីជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៦៤"ឃ" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៤របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចតម្រូវឱ្យអាជ្ញាធរឃុំពត់សរ ទទួលខុសត្រូវខាងរដ្ឋប្បវេណី ដោយពុំទាន់ចាត់របៀបបញ្ចូលជាភាគីក្នុងសំណុំរឿង ។

-បានឃើញសារណា ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៥ របស់ឈ្មោះឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ "ជាម្ចាស់បណ្តឹងសាទុក្ខ" ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៥ របស់ឈ្មោះចិន ខុន "ជាចុងបណ្តឹងសាទុក្ខ" ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះចិន ខុន ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ ពីបទ ធ្វើមនុស្សឃាតដោយ

ចេតនា ប្រព្រឹត្តនៅភូមិក្រូច ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៩ តាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានស្តាប់ក្រឡាបញ្ជីអានសារណារបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ ចិន ខុន "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ១៩៩៩ វេលាម៉ោង៨យប់ រូបខ្ញុំបាទដែលជាកងជីវពល ឃុំពត់សរ ក្រោយពេលដែលបានទទួលដំណឹងថា មានជនមួយក្រុមយកប្រដាប់ឆក់ត្រីខុសច្បាប់ទៅឆក់ រូបខ្ញុំបាទក៏បានទៅមើលហើយស្រែកថា កុំធ្វើដូច្នេះ តែពួកគេមិនស្តាប់ខ្ញុំបាទក៏បាញ់២គ្រាប់ឡើងទៅលើ ដើម្បីឱ្យអ្នកទាំងអស់ឈប់ឆក់ត្រី និង យកសំភារៈដើម្បីបំផ្លាញចោទ ខ្ញុំបាទសូមបញ្ជាក់ថា នៅពេលបាញ់មិនមែនតែរូបខ្ញុំម្នាក់ទេ ជាអ្នកបាញ់ គឺមានឈ្មោះឈួន ឈិន ក៏បានបាញ់ដែរ តែគេមិនត្រូវចាប់ខ្លួន ។ ខ្ញុំបាទសូមសំណូមពរអោយឃុំពត់សរ ចេញសងជំនួសខ្ញុំបាទ ហើយសូមរក្សាសាលដីការបស់សាលាឧទ្ធរណ៍លេខ ៦៤ "ឃ" នៅដដែល ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះទី ប៉ោ "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : ខ្ញុំបាទគ្មានយល់បល់អ្វីទេ សូមឯកឧត្តមប្រធានមេត្តាសំរេច ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសំ ចំរើន ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះចិន ខុន "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : សូមឯកឧត្តម មេត្តាសំរេចតំកល់សាលដីកាព្រហ្មទណ្ឌលេខ ៦៤"ឃ" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ នៅដដែល ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នៅពេលជំនុំជំរះថា : គ្មានយោបល់អ្វីបន្ថែមទៀតទេ សូមក្រុមប្រឹក្សាមេត្តាសំរេច ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណាក្នុងបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ , ចម្លើយរបស់ឈ្មោះចិន ខុន និង សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា ពាក្យបណ្តឹងសាទុក្ខលេខ១១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ របស់អគ្គព្រះរាជអាជ្ញា សាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនរងគ្រោះពិតជាបានទទួលមរណៈភាពដោយការបាញ់របស់កងជីវពល តាមការចាត់តាំងរបស់អាជ្ញាធរ ឃុំពត់សរ ប្រាកដមែន ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចអោយអាជ្ញាធរឃុំពត់សរ សងជម្ងឺចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណី ជាការត្រឹមត្រូវហើយ ប៉ុន្តែការមិនបានបញ្ចូលអាជ្ញាធរឃុំពត់សរនេះមកជាភាគីមួយនៃរឿងក្តីនេះ ជាការពុំត្រឹមត្រូវទេ ដែលគប្បីទុកជាមោឃៈចំណុចនេះ ដើម្បីការពារសិទ្ធតវ៉ារបស់អាជ្ញាធរឃុំពត់សរ និង ជាប្រយោជន៍ច្បាប់ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៦៤"ឃ" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលា-ឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ ប៉ុន្តែគតិច្បាប់ មានការខុសឆ្គងត្រង់ពុំបានបញ្ចូលអ្នកទទួលខុសត្រូវខាងសំណងរដ្ឋប្បវេណីមកជាភាគីនៃរឿងក្តី ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី

១-ទទួលបណ្តឹងសាទុក្ខលេខ១១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៦៤"ឃ" ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងត្រង់ចំណុចបង្គាប់អោយអាជ្ញាធរឃុំពត់សរ សងជម្ងឺចិត្តជាប្រាក់ទៅឈ្មោះទី ប៉ោ ជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៦៥ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះឡើងវិញត្រង់ចំណុចបង្គាប់អោយអាជ្ញាធរ ឃុំពត់សរ សងជម្ងឺចិត្តជាប្រាក់ទៅឈ្មោះទី ប៉ោ ជាដើមបណ្តឹងរដ្ឋប្បវេណី ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៦ ។